អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ៤ ខែ មករា ឆ្នាំ ២០១២

# សេចក្តីប្រកាសព័ត៌មាន

## អ.វ.ត.ក បានសម្រេចលើសផែនការក្នុងការទទួលអ្នកមកទស្សនាចំនួនជាង ១០០.០០០ នាក់

នៅក្នុងឆ្នាំ ២០១១ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) មានអ្នកមកទស្សនាសរុបចំនួន ៤៤.៥៤៣ នាក់។ ចំនួននេះបានធ្វើឲ្យ អ.វ.ត.ក សម្រេចលើសផែនការក្នុងការទទួលអ្នកមកទស្សនានៅតុលាការនេះជាង ១០០.០០០ នាក់ ចាប់តាំងពីពេលបើកសវនាការដំបូងរបស់ខ្លួននៅខែ កុម្ភៈ ឆ្នាំ ២០០៩ មក។ ចន្លោះពីថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៩ រហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១១ អ្នកមកទស្សនានៅ អ.វ.ត.ក មានចំនួន ១១១.៥៤៣ នាក់។

ចំនួនអ្នកមកទស្សនាសរុបនេះរួមទាំងអ្នកមកទស្សនាក្នុងពេលសវនាការសាធារណៈ និងអ្នកចូលរួមក្នុងកម្មវិធីទស្សនកិច្ចសិក្សានៅ អ.វ.ត.ក។ នេះជាកម្មវិធីសិក្សាអប់រំរយៈពេលមួយថ្ងៃ ដែលនៅក្នុងកម្មវិធីនេះ អ.វ.ត.ក នាំប្រជាជនពីគ្រប់ទិសទីទាំងអស់នៃប្រទេសកម្ពុជាមកទស្សនាសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ទីកន្លែងរំឭកវិញ្ញាណក្ខន្ធវាលពិឃាតជើងឯក និងមក អ.វ.ត.ក។ នៅពេលទស្សនា អ.វ.ត.ក អ្នកចូលរួមមានឱកាសសាកសួរសំណួរផ្សេងៗដែលពួកគេចង់ដឹងពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីដែលកំពុងដំណើរការនៅតុលាការនេះ។

សវនាការចំនួន ២៥ ថ្ងៃ នៅឆ្នាំ ២០១១ មានអ្នកទស្សនាសរុបចំនួន ១៨.៦២៣ ហើយអ្នកទស្សនាចំនួន ២៥.៩២០ នាក់ទៀតបានចូលរួមកម្មវិធីទស្សនកិច្ចសិក្សានៅ អ.វ.ត.ក។

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌដង្កោ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh

Original EN: 00763939-00763939

ប្រសិនបើមានមូលនិធិគ្រប់គ្រាន់ អ.វ.ត.ក នឹងបន្តអនុវត្តកម្មវិធីទស្សនកិច្ចសិក្សារបស់ខ្លួន ព្រមទាំងផ្តល់សេវាដឹកជញ្ជូនដោយឥតគិតថ្លៃដល់អ្នកមកចូលរួមសវនាការជាក្រុមពីគ្រប់ទិសទីនៃប្រទេសកម្ពុជាក្នុងឆ្នាំ ២០១២។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖


លោក **ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទដៃ៖ +855(0)-12 488 023
ទូរស័ព្ទ៖ +855 23 219 841 លេខបន្ត៖ 6169
សារអេឡិចត្រូនិក៖ olsenl@un.org

លោក **នេត ភក្ត្រា**
មន្ត្រីព័ត៌មាន
ទូរស័ព្ទដៃ៖ +855 (0) 12 483 283
សារអេឡិចត្រូនិក៖ neth.pheaktra@eccc.gov.kh


ឧបសម្ព័ន្ធ៖ តារាងអ្នកមកទស្សនាពីខែ មីនា ឆ្នាំ ២០០៩ ដល់ ខែ ធ្នូ ឆ្នាំ ២០១១



Original EN: 00763939-00763939